CAMBODIA RICE FEDERATION

# របាយការណ៍សង្ខេបនៃការនាំចេញអង្ករបស់កម្ពុជា
# SUMMARY REPORT OF CAMBODIA'S RICE EXPORT IN MAY 2021

ខែឧសភា ឆ្នាំ២០២១ _ May 2021



**«អង្ករកម្ពុជាបាននាំចេញទៅកាន់ទីផ្សារប្រទេសចិនច្រើនជាងគេ រហូតដល់ជិត៥២% នៃការនាំចេញសរុប ក្នុងរយៈពេល៥ខែ នៃឆ្នាំ២០២១ ដែលគិតជាទឹកប្រាក់ចំនួន ៧៧.៥២ លានដុល្លារសហរដ្ឋអាមេរិក»**

ក្នុងរយៈពេល៥ខែ នៃឆ្នាំ២០២១នេះ កម្ពុជាបានសម្រេចការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិចំនួន ៤៧ប្រទេស ក្នុងបរិមាណសរុប ២៣៣ ០៣១ តោន ដែលគិតជាទឹកប្រាក់ទទួលបាន ១៦៦.៨១ លានដុល្លារសហរដ្ឋអាមេរិក។ បរិមាណអង្ករសរុបជាង ១២ម៉ឺនតោន ឬ ជិត ៥២% ត្រូវបាននាំទៅកាន់ប្រទេសចិនរួមទាំង ហុងកុង និង ម៉ាកាវ ដែលគិតជាទឹកប្រាក់ ៧៧.៥២ លានដុល្លារសហរដ្ឋអាមេរិក។

ដោយវិបត្តិកូវីដ១៩ ដែលប៉ះពាល់ដល់ចរន្តនៃលំហូរពាណិជ្ជកម្ម និងវិស័យផ្សេងដែលគាំទ្រដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ ជាអាទ៍ កង្វះកុងតែន័រ និងការឡើងថ្លៃដឹកជញ្ជូនផ្លូវឆ្ងាយតាមសមុទ្រ ជាពិសេសទៅសហគមន៍អឺរ៉ុប បានធ្វើឱ្យបរិមាណនៃការនាំអង្ករចេញ ជារួមបានធ្លាក់ចុះ ជាង ៣៤% ហើយទីផ្សារដែលប៉ះពាល់ធំជាងគេ គឺទីផ្សារសហគមន៍

អឺរ៉ុបដែលធ្លាប់កាន់ចំណែកនៃការនាំចេញសរុបជាង៣៤% ប្រហែលគ្នាទៅនឹងទីផ្សារចិន ដែលមានចំនួន ៣៨% នៅក្នុងរយៈពេល៥ខែដូចគ្នានៅក្នុងឆ្នាំ២០២០ ហើយបើគិតជាបរិមាណ គឺប្រមាណជាង ១២ម៉ឺនតោន នៅក្នុងរយៈពេល៥ខែ នៃឆ្នាំ២០២០ មកត្រឹមជិត៦ម៉ឺនតោន ឬជាង ២៥% នៃការនាំចេញសរុបក្នុង៥ខែ ឆ្នាំ២០២១ ។ ក្រៅពីនេះ ការនាំចេញទៅប្រទេសផ្សេងៗដូចជាសហរដ្ឋអាមេរិក ក៏បានធ្លាក់ចុះពី ជាង ២០០០តោន មកត្រឹមជាង ២០០តោន ផងដែរ។

បើយើងក្រឡេកមកលើតម្លៃនៃការដឹកជញ្ជូន នៅក្នុងត្រីមាសទី១នៃឆ្នាំ២០២០ តម្លៃសម្រាប់កុងតែន័រ ២០ហ្វីត ពីតំបន់អាស៊ីអាគ្នេយ៍ទៅសហគមន៍អ៊ឺរ៉ុប មិនលើសពី១៥០០ដុល្លារសហរដ្ឋអាមេរិកនោះទេ តែនៅក្នុងត្រីមាសទី១ឆ្នាំ ២០២១ បានកើនឡើងរហូតដល់ជិត ៨០០០ដុល្លារ/TEU ក្នុងមួយកុងតែន័រ ២០ហ្វីត។ តម្លៃនៃការដឹកជញ្ជូនទៅកាន់សហរដ្ឋអាមេរិក បានកើនពីជាង ២៥០០ដុល្លារទៅ ១៤០០០ដុល្លារ/FEU ក្នុងមួយកុងតែន័រ ៤០ហ្វីត ហើយនឹងបន្តកើនឡើងនៅក្នុងខែមិថុនាខាងមុខនេះទៀត។

សម្រាប់ខែឧសភា ឆ្នាំ២០២១ កម្ពុជាបាននាំចេញអង្ករចំនួន ៤០ ៥៣៦តោន ទទួលបានទឹកប្រាក់ ២៦.៧១ លានដុល្លារសហរដ្ឋអាមេរិក។ ហើយទីផ្សារដែលធំជាងគេគឺ ប្រទេសចិន ៤០% ប្រទេសនៅក្នុងទ្វីបអឺរ៉ុប ចំនួន៣០% ទីផ្សារក្នុងអាស៊ានជិត១២% និង ទីផ្សារបណ្ដាប្រទេសផ្សេងៗមានជិត ១៨%។

រីឯប្រភេទអង្ករនាំចេញ ក្នុងខែឧសភានេះ អង្ករក្រអូប បាននាំចេញ ៧៤% ចំពោះអង្ករសគ្រាប់វែងវិញ បាននាំចេញ ២១% អង្ករចំហុយ ៣% និងចុងក្រោយ ២% គឺអង្ករសរីរាង្គ។

ការនាំចេញអង្ករទៅកាន់ទីផ្សារគោលដៅ
រយៈពេល៥ខែ ឆ្នាំ២០២១




ការនាំចេញអង្ករតាមប្រភេទ ខែឧសភា ឆ្នាំ២០២១




**រៀបរៀងដោយ**

លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា
ចេញផ្សាយថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១



## China remains the biggest Cambodian rice export's market, accounted for almost 52% of overall export in 5 months of 2021, generating in value USD 77.52 Million

In the 5 month of 2021, Cambodia has achieved its rice export to 47 countries destination in the volume of 233,031 Metric Tons (MT), and generating in value of USD 166.81 Million. More than 52% of overall export or equal to more than 120,000 MT of milled-rice has exported to China market, including Hong Kong, Macau, in which bring about almost USD 77.52 Million as the value.

COVID-19 has continued bumping the trading flow as well as affected on other sectors that relevant to internal trading for such as the container shortage and the shipping price rising especially to the European Union (EU) destination, resulting in the overall volume of rice exports down by more than 34%, and the most affected market is the EU markets, which used to account for more than 34% of total exports; quite similar to about 38 percent of the Chinese market, and in terms of volume EU market was about 120,000 MT in the first 5 months of 2020 but fell to nearly 60,000 MT or over 25% of total exports in the same period of 2021. Exports to other countries, such as the United States, also fell from more than 2,000 MT to more than 200 MT.

If we look at the cost of shipping in the first quarter of 2020, the price for a 20-foot container from Southeast Asia to the European Union did not exceed USD 1,500, but in the first quarter of 2021 the price is jumped up to nearly $ 8,000 / TEU per 20-foot container. Moreover, shipping costs to the United States have risen from more than $ 2,500 to $ 14,000 / FEU per 40-foot container and will continue to rise in June.

In this May 2021, Cambodia exports 40,536 MT of Milled rice, receiving USD 26.71 Million. The top export's market is China, accounted for 40% of overall export, following by 30% to countries in Europe Continent, and ASEAN get 12%, also the other countries destination is 18%.

In term of rice export by varieties in this May 2021, premium fragrant and fragrant rice accounted for 74%, long grain white rice accounted for 21%, parboiled rice is 3%, and the last 2% is organic rice.

## RICE EXPORT BY DESTINATIONS 5 MONTHS OF 2021




## RICE EXPORT BY VARIETIES MAY 2021




## PREPARED BY

Secretariat of Cambodia Rice Federation (CRF)
02 June 2021

Source: Ministry of Agriculture Forestry and Fisheries, and General Department of Customs and Excise of Cambodia